**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី១ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧**

**រៀបចំដោយ៖ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**

**នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**ឧបត្ថម្ភដោយ៖ ថវិកាជាតិ**

**១. សេចក្តីផ្តើម៖**

នៅព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី១ សម្រាប់ឆ្នាំ២០១៧ ក្រោមការដឹកនាំរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត តៀង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង-ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលចំនួន៣៥រូប។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

**២. គោលបំណងនៃកិច្ចប្រជុំ៖**

ដើម្បីបង្ហាញពីរបាយការណ៍វឌ្ឍនភាព សមិទ្ធផល និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ ព្រមទាំងពិភាក្សា សម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈ ដូចខាងក្រោម៖

-មតិស្វាគមន៍ និងគោលបំណង នៃកិច្ចប្រជុំ

-របាយការណ៍ប្រចាំខែ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-បង្ហាញពីបច្ចុប្បន្នភាពនៃការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅប្រទេសកម្ពុជា

-បទបង្ហាញពីផែនការសកម្មភាពប្រចាំឆ្នាំ២០១៧ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-បញ្ហាផ្សេងៗ

**៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖**

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមវេជ្ជបណ្ឌិត តៀង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណ ដល់សមាជិក-សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។





**ប្រធានបទទី១៖ ឯកឧត្តមវេជ្ជបណ្ឌិត ជា ម៉ៅ** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីរបាយការណ៍សង្ខេប របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានធ្វើក្នុងខែមករា និងខែកុម្ភៈ ឆ្នាំ២០១៧ ដូចខាងក្រោម៖

- ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧ នៅទីស្នាក់ការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមការងាររួមរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍លើការងារប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាតំណាងស្ថាប័ន ក្រសួងពាក់ព័ន្ធ តំណាងទីភ្នាក់ងារដៃគូអភិវឌ្ឍន៍ ម្ចាស់ជំនួយ តំណាងអង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអង្គការសហប្រជាជាតិ។ កិច្ចប្រជុំនេះ បានផ្តោតលើការវិវត្តន៍សូចនាកររួមរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ឆ្នាំកន្លងទៅ(JMI2015-2016) និងពិនិត្យមើលសូចនាករឆ្នាំ ២០១៧-២០១៨ របស់ CRDB/CDC ដោយផ្តោតលើការសម្រេចចិត្តរបស់រដ្ឋាភិបាល ក្នុងការបញ្ចប់ការរាលដាលមេរោគអេដស៍នៅឆ្នាំ២០២៥ នៅក្នុងបរិបទមួយដែលដៃគូអភិវឌ្ឍន៍កំពុងកាត់បន្ថយជំនួយ និងការបង្កើនថវិកាជាតិ ដើម្បីរួមចំណែកពង្រឹងភាពជាម្ចាស់ក្នុងការឆ្លើយតបឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល ក្នុងការត្រៀមខ្លួនជានាការឆ្លើយតបប្រកបដោយចីរភាព។
- ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ បានចូលរួមក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះ ផែនការ និងការកាត់បន្ថយភាពក្រីក្រ (TWG-PPR) ស្តីពីការពិនិត្យឡើងវិញ ពាក់កណ្តាលអាណត្តិ លើផែនការអភិវឌ្ឍន៍ជាតិ (NSDP ២០១៤-២០១៨) ដើម្បីពិនិត្យពិភាក្សាពីវឌ្ឍនភាពនៃការងារ និងទិសដៅដែលត្រូវអនុវត្ត។ ជាលទ្ធផលយើងបានកែសម្រួលអត្ថន័យ និងព័ត៌មានទាក់ទងនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើឯកសារការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិលើផែនការអភិវឌ្ឍន៍ជាតិ (NSDP ២០១៤-២០១៨) និងបានផ្តល់ជូនក្រសួងផែនការរួចរាល់ហើយ។
- ថ្ងៃទី០៦-០៧ ខែកុម្ភៈ ឆ្នាំ២០១៧ បានចូលរួមកិច្ចប្រជុំនៃបណ្តាញក្រុមការងារបច្ចេកទេសចម្រុះ(TWG Network Meeting) នៅខេត្តព្រះសីហនុ ដើម្បីពិនិត្យមើលប្រសិទ្ធភាពនៃការអភិវឌ្ឍន៍ (Global Perspective in Development) និងទស្សនៈវិស័យស្តីអំពីប្រសិទ្ធភាពក្នុងការពិនិត្យឡើងវិញ នូវវឌ្ឍនៈភាពនៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិដើម្បីអភិវឌ្ឍន៍ (NSDP 2014-2018) និងការវាយតម្លៃស្ថានភាពហិរញ្ញវត្ថុនៃការអភិវឌ្ឍន៍(Development Finance Assessment) ដោយពិភាក្សាពីការរៀបចំផែនការ និងការជ្រើសរើសកម្មវិធីទៅតាមផ្នែកនីមួយៗក្នុងការជំរុញអោយមានការរីកចម្រើន ក្នុងការអនុវត្ត JMI និងពិនិត្យមើលលទ្ធភាពហិរញ្ញប្បទានក្នុងការអភិវឌ្ឍន៍ ដែលគោលដៅនេះ គឺសង្កត់ធ្ងន់លើការពង្រឹងយន្តការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ។
- ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៧ នៅទីលានកំសាន្តកោះពេជ្រ ឯកឧត្តមអគ្គលេខាធិការ បានចូលរួមការប្រគំតន្ត្រីផ្សព្វផ្សាយពីការបង្ការការឆ្លងមេរោគអេដស៍ ជូនដល់ប្អូនៗយុវវ័យពីគ្រប់មជ្ឈដ្ឋាន ដែលរៀបចំដោយអង្គការ AHF Cambodia និងដោយមានការគាំទ្រពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងសាលារាជធានីភ្នំពេញ។
- ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៧ នាទីស្នាក់ការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយពីការបង្ការនៃការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ ដល់យុវវ័យនៅក្នុងឱកាសបុណ្យទិវានៃក្តីស្រឡាញ់។
- ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានអញ្ជើញជាអធិបតីក្នុងសិក្ខាសាលា ស្តីពីការវាយតម្លៃសកម្មភាពមេរោគអេដស៍ របស់គណៈកម្មាធិការ

ប្រយុទ្ធនឹងជំងឺអេដស៍ខេត្តកោះកុង។ សិក្ខាសាលានេះ មានការចូលរួមពីថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មន្ទីរពាក់ព័ន្ធនានា និងអង្គការសង្គមស៊ីវិលនៅជុំវិញខេត្តកោះកុង។ សិក្ខាសាលានេះ សំដៅពង្រឹងការអនុវត្តសេចក្តីជូនដំណឹងលេខ ៦៦សជណ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលស្តីពីការលើកកម្ពស់ការប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយ ព្រោះថានេះជាវិធានការដ៏មានប្រសិទ្ធភាពមួយ ដើម្បីកាត់បន្ថយអត្រារីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍។

- បានចុះអភិបាលកិច្ចលើការវិវឌ្ឍន៍រីកចម្រើនក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅថ្នាក់ឃុំ/សង្កាត់ ក្នុងខេត្តប៉ៃលិន ខេត្តតាកែវ ខេត្តបាត់ដំបង និងខេត្តកំពង់ធំ ដើម្បី៖

  -ពិនិត្យមើលស្ថានភាពការឆ្លើយតបជាមួយមេរោគអេដស៍ នៅក្នុងខេត្ត និងក្នុងសហគមន៍។

  -ពិនិត្យមើលលទ្ធផលនៃការបញ្ចូលគ្រួសារក្រីក្រ ដែលមានសមាជិកផ្ទុកមេរោគអេដស៍ ក្នុងនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅថ្នាក់ឃុំ/សង្កាត់។

  -ការពិនិត្យមើលការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល ក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងខេត្ត។

- ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧ នាទីស្នាក់ការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលមូលនិធិសកលនៅកម្ពុជា បានចូលរួមកិច្ចប្រជុំពិភាក្សាជាមួយអង្គការសង្គមស៊ីវិល និងបណ្តាញសហគមន៍របស់ក្រុមប្រឈមមុខខ្ពស់ និងអ្នករស់នៅជាមួយមេរោគអេដស៍ ដើម្បីពង្រឹងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាព និងចីរភាព។

- ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកឧត្តមអគ្គលេខាធិការ បានធ្វើបទឧទ្ទេសនាមពីមេរោគអេដស៍ និងជំងឺអេដស៍ ដល់និស្សិតវេជ្ជសាស្ត្រ ទន្តសាស្ត្រ និង ឱសថសាស្ត្រ នៃវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ក្នុងគោលបំណងដើម្បីអប់រំ ផ្សព្វផ្សាយដល់ប្អូនៗនិស្សិតឱ្យយល់ដឹងកាន់តែច្បាស់ពីមេរោគអេដស៍ និងការការពារមិនឱ្យឆ្លងមេរោគអេដស៍ ដូចសុភាសិតគេថា "ការពារប្រសើរជាងព្យាបាល "។

- ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលជំនួយមូលនិធិសកល បានធ្វើជាអធិបតីក្នុងសិក្ខាសាលាពិគ្រោះយោបល់លើគម្រោងកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ ដែលរៀបចំសហការដោយគណៈកម្មាធិការសម្របសម្រួលជំនួយមូលនិធិសកល អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។ សិក្ខាសាលានេះ មានការចូលរួមពីកម្មវិធីជាតិ ក្រុមការងារមូលនិធិសកលប្រចាំប្រទេស តំណាងអង្គការសុខភាពពិភពលោក តំណាងកម្មវិធីអេដស៍អង្គការសហប្រជាជាតិ និងដៃគូសង្គមស៊ីវិលក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍។ សិក្ខាសាលានេះមានគោលបំណងពិភាក្សាលើការរៀបចំគម្រោងសំណើថវិកាកម្មវិធីអេដស៍ទៅមូលនិធិសកលសម្រាប់ឆ្នាំ២០១៨-២០២០។

**ផែនការសកម្មភាព និងទិសដៅបន្ត៖**

- បន្តអនុវត្តផែនការចុះអភិបាលកិច្ចលើការអភិវឌ្ឍន៍រីកចម្រើន ក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅតាមបណ្តាខេត្តមួយចំនួនទៀត។
- ត្រៀមរៀបចំកិច្ចប្រជុំលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ ព្រមទាំងការរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ ប្រចាំខែ និងត្រីមាស។
- បន្តចុះអភិបាលកិច្ច លើការអនុវត្តន៍ការងារប្រយុទ្ធនឹងជំងឺអេដស៍ និងការបង្កបរិយាកាស អំណោយផលនៃការអនុវត្តន៍កម្មវិធីដៃគូសហគមន៍ សម្រាប់ប្រជាជនប្រឈមមុខខ្ពស់ នៅខេត្តកោះកុង និង កំពត។

ក្រោយពីបង្ហាញចប់ ឯកឧត្តមប្រធានអង្គប្រជុំ បានស្នើឱ្យបន្ថែមនូវសកម្មភាពដែលសមាជិកក្រុមការងារបានធ្វើកន្លងមក សម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**តំណាងក្រសួងអប់រំ យុវជន និងកីឡា៖** បានចេញសេចក្តីណែនាំទៅដល់សិស្ស និស្សិត កុំឱ្យមានការ ភ្លើតភ្លើន នៅក្នុងឱកាសបុណ្យទិវានៃក្តីស្រលាញ់ នាថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧។

ទាក់ទងទៅនឹងកម្មវិធីសិក្សាថ្មីពីឆ្នាំ២០១៧-២០២៥ មានមុខវិជ្ជាអប់រំសុខភាព ដោយក្នុងនោះមានទាំងមេរៀនទាក់ទងទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ផងដែរ គឺរយៈពេលមួយម៉ោងក្នុងមួយសប្តាហ៍ តាំងពីថ្នាក់ទី១-១២។

**តំណាងក្រសួងកិច្ចការនារី៖**

-បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីកំណត់ពីតម្រូវការឆ្លើយតបនឹងយេនឌ័រ និងមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងគោលបំណងស្វែងយល់ពីបច្ចុប្បន្នភាពនៃការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅឃុំកា និងតម្រូវការជាក់ស្តែងរបស់ពួកគាត់ផងដែរ។

-បានរៀបចំវគ្គបណ្តុះបណ្តាលពីយេនឌ័រ សិទ្ធិ ការរៀបចំផែនការសកម្មភាព និងថវិកាឆ្លើយតបយេនឌ័រ និងមេរោគអេដស៍ ជូនដល់សមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ថ្នាក់ដឹកនាំភូមិ មណ្ឌលសុខភាពកា តំណាងអ្នកផ្ទុកមេរោគអេដស៍ និងអង្គការ BFD សរុបចំនួន២៧នាក់។

**តំណាងក្រសួងការពារជាតិ៖** ដោយបានសហការណ៍ជាមួយអង្គការ AHF បានអនុវត្តនូវសកម្មភាពដូចខាងក្រោម៖

-ពីថ្ងៃទី១៥-៣០ ខែធ្នូ ឆ្នាំ២០១៦ បានចុះប្រមូលព័ត៌មានតាមបណ្តាអង្គភាពកងទ័ពតាមបណ្តោយព្រំដែនកម្ពុជា-ថៃ បានចំនួន១៨ អង្គភាព ដោយសុំឱ្យមានការគាំទ្រកម្មវិធីពីមេបញ្ជាការអង្គភាពនីមួយៗ ក្នុងការចុះទៅអនុវត្តសកម្មភាព។

-ពីថ្ងៃទី២១-២៤ ខែកុម្ភៈ ឆ្នាំ២០១៧ បានបណ្តុះបណ្តាលគ្រូបង្គោល ក្នុងការធ្វើតេស្តឈាមរកមេរោគអេដស៍ និងស្វាយ ដោយមានសិក្ខាកាមចូលរួមចំនួន២៦នាក់ នៅមន្ទីរពេទ្យយុទ្ធភូមិភាគទី៤។

**តំណាងក្រសួងទំនាក់ទំនងជាមួយសភា ព្រឹទ្ធសភា និងអធិការកិច្ច៖** បានចុះផ្សព្វផ្សាយច្បាប់ស្តីពីគ្រឿងញៀន នៅស្រុក ស្អាង ខេត្តកណ្តាល ហើយក៏បានបញ្ជ្រាបពីបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ ពិសេសច្បាប់អេដស៍ និងយុទ្ធសាស្ត្រ៣-០។

**តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាៈ**

-បានរៀបចំបច្ចុប្បន្នភាពរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង

-បានធ្វើបច្ចុប្បន្នភាពនៃទិន្នន័យទៅលើកុមារ ជនពិការ ដើម្បីដឹងចំនួនអ្នកផ្ទុកមេរោគអេដស៍ ក្នុងការធ្វើផែនការឆ្លើយតបឱ្យស្របតាមស្ថានភាពជាក់ស្តែង។

-បានធ្វើការផ្សព្វផ្សាយនៅតាមបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ ចំនួន៤ សរុប៨០០នាក់ ក្រោមប្រធានបទការអប់រំទាក់ទងសង្គមសម្រាប់ស្ត្រី និងគ្រួសារខ្មែរ ផ្សាភ្ជាប់ទៅនឹងទិវានៃក្តីស្រលាញ់។

-បានធ្វើការប្រជុំជាមួយអង្គការចំនួន៦ តើសេវាអ្វីខ្លះដែលពួកគាត់បានផ្តល់ដល់អ្នកផ្ទុកមេរោគអេដស៍ និងសេវាដែលបានផ្តល់ឆ្លើយតបចំពោះពួកគាត់ដែរឬទេ?

**តំណាងមន្ទីរសុខាភិបាលរាជធានីភ្នំពេញៈ** បានអញ្ជើញអង្គការដែលធ្វើការងារប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់មកពិនិត្យមើលពីសុពលភាពនៃការចុះអនុស្សរណៈយោគយល់គ្នារវាងមន្ទីរសុខាភិបាលរាជធានីភ្នំពេញ និងអង្គការដៃគូ ហើយអង្គការដែលមិនទាន់បានចុះ ត្រូវតែចុះជាមួយនឹងមន្ទីរ ដើម្បីដឹងពីទីតាំង និងសកម្មភាព ដែលត្រូវធ្វើជៀសវាងការជាន់សកម្មភាពគ្នា។

**ប្រធានបទទី២ៈ ឯកឧត្តម វេជ្ជបណ្ឌិត ហោ ប៊ុនឡេង** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីបច្ចុប្បន្នភាពនៃការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅប្រទេសកម្ពុជាៈ

មេរោគអេដស៍បានរកឃើញដំបូងបំផុតនៅកម្ពុជាតាម រយៈអ្នកផ្តល់ឈាមនៅមជ្ឈមណ្ឌលជាតិផ្តល់ឈាមនៅឆ្នាំ១៩៩១ ក្រោយទទួលបាននូវជំនួយតេស្តរកមេរោគអេដស៍ពីអង្គការកាកបាទក្រហមអន្តរជាតិ។

ជំងឺអេដស៍បានរកឃើញដំបូងបំផុតនៅកម្ពុជា តាមរយៈអ្នកជំងឺដែលមកស្វែងរកសេវាថែទាំ និងព្យាបាលជំងឺឱកាសនិយមនៅមន្ទីរពេទ្យកាល់ម៉ែតឆ្នាំ១៩៩៣។

ប្រវត្តិនៃការតាមដានការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាៈ ដំបូងយើងធ្វើការអង្កេតលើកទី១ នៅភ្នំពេញ និងលើកទី២ នៅក្រុងព្រះសីហនុ បន្ទាប់មកធ្វើប្រព័ន្ធអង្កេតមេរោគអេដស៍ប្រចាំឆ្នាំលើកទី១ នៅឆ្នាំ១៩៩៥ ប្រព័ន្ធអង្កេតការប្រព្រឹត្តប្រឈមការចម្លងមេរោគអេដស៍ប្រចាំឆ្នាំលើកទី១ នៅឆ្នាំ១៩៩៧ បន្ទាប់មកយើងធ្វើប្រព័ន្ធអង្កេតមេរោគអេដស៍ប្រចាំ៣ឆ្នាំម្តងលើកទី១នៅឆ្នាំ២០០៣។ ប្រព័ន្ធអង្កេតការប្រព្រឹត្តប្រឈមការចម្លងមេរោគអេដស៍ប្រចាំ៣ឆ្នាំម្តងលើកទី១ នៅឆ្នាំ២០០៦ និងប្រព័ន្ធអង្កេតរួមគ្នាមេរោគអេដស៍ និងការប្រព្រឹត្តប្រចាំ៣ឆ្នាំម្តងលើកទី១ នៅឆ្នាំ២០១៦។

ការវិវត្តន៍នៃការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាៈ ការផ្ទុះឡើងនៃមេរោគអេដស៍ នាឆ្នាំ១៩៩១ ដែលការរាលដាលមេរោគអេដស៍ មានលក្ខណៈប្រមូលផ្តុំ បន្ទាប់មកការរាលដាលមេរោគអេដស៍មានលក្ខណៈទូទៅ។

ជារួមនាពេលបច្ចុប្បន្ន អត្រារាលដាលមេរោគអេដស៍នៅកម្ពុជា កំពុងតែឋិតនៅក្នុងដំណាក់កាលធ្លាក់ចុះជាបន្តបន្ទាប់ ហើយកម្ពុជាពិតជាអាចគ្រប់គ្រងបានទាំងស្រុងនូវការឆ្លងមេរោគអេដស៍ថ្មីនៅក្នុងចំណោមក្រុមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ។ រលកទី២នៃការរាលដាលមេរោគអេដស៍ អាចផ្ទុះឡើងនៅក្នុងក្រុមបុរសស្រឡាញ់បុរស ក្រុមប្រើគ្រឿងញៀន និងក្រុមយុវវ័យ។

**<u>ប្រធានបទទី៣</u>៖ លោកវេជ្ជបណ្ឌិត ទេព ណារ៉ុធ** ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីផែនការសកម្មភាពប្រចាំឆ្នាំ២០១៧ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ៖

ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយនិងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៤៖

-<u>យុទ្ធសាស្ត្រ</u>១៖ផ្តួចផ្តើមកម្មវិធីបង្ការមេរោគអេដស៍ដែលមានគុណភាព និងប្រសិទ្ធភាពខ្ពស់ ( Prevention )

-<u>យុទ្ធសាស្ត្រ</u>២៖បង្កើន និងរក្សាគុណភាព ការគ្របដណ្តប់ និងការរក្សាទុកគ្រប់ជំហានទាំងអស់នៃការថែទាំបន្ត។

-<u>យុទ្ធសាស្ត្រ</u>៣៖ កាត់បន្ថយផលប៉ះពាល់នៃមេរោគអេដស៍ និងជំងឺអេដស៍ ( Impact Mitigation )

-<u>យុទ្ធសាស្ត្រ</u>៤៖ ដឹកនាំ សម្របសម្រួលភាគីពាក់ព័ន្ធ កៀរគរ និងបែងចែកធនធាន។

-<u>យុទ្ធសាស្ត្រ</u>៥៖ បង្កើតបរិយាកាសគាំទ្រ ( Enabling Environment )

-<u>យុទ្ធសាស្ត្រ</u>៦៖ ពង្រឹងប្រព័ន្ធតាមដាន និងវាយតម្លៃតែមួយ ( M&E System )

**ផែនការសកម្មភាពរបស់ អ.ជ.ប.ជ.អ ឆ្នាំ២០១៧៖**

1. បន្តអនុវត្តគោលការណ៍៧ចំណុចរបស់រាជរដ្ឋាភិបាល នៃការប្រយុទ្ធនឹងជំងឺអេដស៍ លិខិតលេខ ២០៤៨ សជណ ចុះថ្ងៃ១៧ ខែធ្នូ ឆ្នាំ២០១៣។
2. បន្តធ្វើកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលឆ្នាំ២០១៨-២០២០ ដោយពិនិត្យកម្មវិធីដែលមានស្រាប់ និងកម្មវិធីបន្ថែមនៅពេលថវិកាជំនួយ ធ្លាក់ចុះឆ្ពោះទៅការលុបបំបាត់ការឆ្លងអេដស៍ថ្មីនៅឆ្នាំ២០២៥។
3. បន្តកិច្ចសហការគ្នាជាមួយស្ថាប័នពាក់ព័ន្ធ ជំរុញការអនុវត្តលិខិតលេខ ៦៦ សជណ ស្តីពីវិធានការជំរុញការប្រើប្រាស់ស្រោមអនាម័យ ១០០% នៅគ្រប់គ្រឹះស្ថានកំសាន្តសប្បាយដល់គ្រប់ស្ថាប័នពាក់ព័ន្ធ។
4. បន្តអនុវត្តនិយាមប្រត្តិបត្តិនៃកម្មវិធីផ្តួចផ្តើមភាពជាអ្នកដឹកនាំដៃគូ សហគមន៍ ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
5. បន្តការងារជាមួយក្រសួងផែនការក្នុងការវាយតម្លៃស្ថានភាពក្រ របស់អ្នកផ្ទុកមេរោគអេដស៍ ដើម្បីមានលទ្ធភាពទទួលបានប័ណ្ណក្រីក្រ។
6. បន្តការជម្រុញការស្នើសុំថវិកាទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការវិភាជថវិកាសម្រាប់កាងារអេដស៍ជាពិសេសកម្មវិធីអេដស៍នៅថ្នាក់ឃុំ/សង្កាត់។
7. បន្តការស្នើសុំការដាក់បញ្ចូលការងារលុបបំបាត់អេដស៍ ទៅក្នុងគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាពរបស់ក្រសួងមហាផ្ទៃ។
8. បន្តពិនិត្យលទ្ធភាព និងបង្កើនប្រសិទ្ធភាពទាក់ទងហិរញ្ញប្បទានក្រៅប្រទេស ក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។ បន្តកម្មវិធីមូលនិធិសកលសម្រាប់ឆ្នាំ២០១៨-២០២០ ក្រុមការងារចម្រុះរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍លើការងារអេដស៍។
9. NAA, MoEYS, MoInfo, MoSVY, MoT, MoLVT, MoND បន្តពង្រីក និងជំរុញការអប់រំផ្សព្វផ្សាយព័ត៌មាន និងចំណេះដឹងស្តីពីការទប់ស្កាត់ការឆ្លងមេរោគអេដស៍ លើក្រុមយុវវ័យ ជនចំណាកស្រុក និងប្រជាជនទូទៅ។

10. បន្តពង្រឹងការងារតាមដាន វាយតម្លៃ និងរបាយការណ៍។

បន្ទាប់មកឯកឧត្តមប្រធានអង្គប្រជុំបានមានប្រសាសន៍ថា៖

-ស្នើគ្រប់ក្រសួង-ស្ថាប័ន ទាំងអស់ផ្ញើនូវរបាយការណ៍សកម្មភាពដែលអនុវត្ត មកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីបញ្ចូលជារបាយការណ៍រួមរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

-គាំទ្រការចុះអនុសារណៈយោគយល់ជាមួយអង្គការសង្គមស៊ីវិល ដែលទទួលខុសត្រូវក្នុងអាណត្តិរបស់ខ្លួន។

ឯកឧត្តមប្រធានអង្គប្រជុំ ក៏បានជម្រាបដល់សមាជិក-សមាជិកានៃអង្គប្រជុំថា កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ នឹងប្រព្រឹត្តទៅនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១១ និង១៥នាទី ថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត។

**ឧបសម្ព័ន្ធ៖**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ភ្នំពេញ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧

**ប្រធាននាយកដ្ឋាន**
**ទាក់ទង និងចលនាប្រភពធនធាន**

ឈសិទ្ធិ

បានឃើញ និងឯកភាព
**អគ្គលេខាធិការ**

**វេជ្ជ.តៃង គន្ធី**

16-3-17

# <u>ឯកសារសម្រាប់ចុះក្នុងគេហទំព័រអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍</u>

កាលពីព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី១ ប្រចាំឆ្នាំ២០១៧ ក្រោមការដឹកនាំរបស់ ឯកឧត្តមវេជ្ជបណ្ឌិត **តេង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង-ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ចំនួន៣៦រូប។

<u>ក្នុងកិច្ចប្រជុំនោះផ្តោតសំខាន់ទៅលើ</u>៖

-របាយការណ៍ប្រចាំខែ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-បទបង្ហាញពីបច្ចុប្បន្នភាពនៃការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅប្រទេសកម្ពុជា

-បទបង្ហាញពីផែនការសកម្មភាពប្រចាំឆ្នាំ២០១៧ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-និងបញ្ហាផ្សេងៗ





16-3-17